# វគ្គ ម៉ោង១អធ្រាត្រយប់ផ្សំដំណេក

គេនៅតែឮសំឡេងនាងយំយ៉ាងខ្សោយៗ។

នេះជាគ្រប់យ៉ាងដែលម៉ូស្គារំពឹងចង់បានទុកមកយូរហើយ។ គេចង់ឲ្យនាងយំច្រើនជាងនេះទៅទៀត បាននាងស្រែកខ្លាំងៗឡើងកាន់តែល្អ។

មនុស្សស្រីម្នាក់នេះមានមុខរឹងខ្លាំងណាស់ ធន់ទ្រាំឈឺបានល្អបំផុតហើយ។ នាងមិនស្រែកឬមួយក៏និយាយប្រកែកទាល់តែសោះទាំងដែលរាងកាយរបស់នាងដែលកំពុងឈឺចាប់ខ្លាំងចំពោះរាត្រីដំបូងនេះ នៅតែអត់ធ្មត់ទ្រាំទ្របានដល់បីដងរួចមកលួច យំខ្សឹកខ្សួលបែរខ្នងគេចមុខម្នាក់ឯង។

ខណៈនេះខាងប្រុសកំពុងដើរត្រឡប់ទៅរកគ្រែវិញជាថ្មីទៀតហើយ។ បែបជានាងដឹងខ្លួនថាគេមកដល់ នឹងលុតជង្គង់មួយជ្រៅៗខ្លាំងៗលើពូក ដឹងថានឹងមានអ្វីបម្រុងកើតឡើងទៀត បានជាស្រីងាកមកយឺតៗថយខ្លួនគេចចេញយ៉ាងលឿនបំផុត។

ម៉ូស្គាឃើញទឹកមុខនាង ភ័យដែលថ្លាល់ប្រឡាក់ ខំយកដៃជូតខ្លាចគេឃើញនាងយំខ្លាចគេអន់ចិត្តដឹង ប៉ុន្តែប្រុសយើងនៅតែរុលចូលយ៉ាងសប្បាយក្រអឺតមុខ។

គេឈានជង្គង់ឡើងដល់លើពូកទាំងសងខាង ព្រមទាំងរំកិលចូលទៅរកខ្លួននាង។ ដៃគេមួយលូកទៅទាញខ្លួនដែលខិតចេញនោះឱ្យនៅផ្ទាំងវិញខិតទៅទៀតលែងបាន។

ទង្វើគេធ្វើឲ្យនាងដូចជាភ័យស្លេកដេកផ្ងារដូចជាទន់ខ្លួនល្មើយ សម្លឹងគេដោយសង្ស័យ។ ប្រុសមាឌធំធ្វើមុខស្មើខាំមាត់តិចៗភ្នែកសម្លក់នាង ដូចជាប្រាប់ថាដល់ពេលទៀតហើយ។

នាងមានសភាពឆ្ងល់ជាខ្លាំង ប៉ុន្តែមិនហាមាត់និយាយអ្វីទាល់តែសោះ ថយខ្លួនយឺតៗទៅរកគែមគ្រែ តែត្រូវខាងប្រុសលូកដៃម្ខាងច្បាមចង្កេះជាប់។

ស្រាប់តែលើកនេះ មិនដូចបីលើកមុនដែលនាងខាំមាត់ទ្រាំស្ងៀមឱ្យម៉ូស្គារុករាននាងបិទភ្នែកទទួលយកការឈឺចាប់ផ្ទួនៗទៀតបែរជាលើកដៃដណ្ដើមភួយមកវិញមិនឱ្យគេទាញសម្រាតចេញ។

នាងអង្វរខ្សាវៗគួរឱ្យអាណិតថា៖

«កុំធ្វើចឹងទៀត ច្រើនដងហើយ!»

ខាងប្រុសសង្កេតឃើញមាត់នាងស្លេកងាំងដូចខ្សោះឈាម តែគេមិននិយាយអ្វីបែរជាប្រើកម្លាំងទាញច្បាមភួយសម្លីចេញមួយទំហឹងលេចត្រដាងរាងកាយសទន់ដែលស្រីខំបិទបាំងប្រទាញការពារ។

សម្លឹងនាងដោយកែវភ្នែកពីក្បាលដល់ចុងជើងដោយកែវភ្នែកគ្មានមេត្តា ម៉ូស្តាហារនិយាយ៖

ចេះរួមមាឌតូចជាងមុនទៀត? មកពីភ័យឬក៏ឈឺ?

នាងលេបទឹកមាត់ផ្សើមបំពង់កសម្លឹងគេនេះចង់សុំចិត្តមេត្តា។ ទោះជាស្រីតូចមិននិយាយតែចិញ្ចើមនិងភ្នែកនាងកំពុងប្រាប់គេថា នាងឈឺណាស់។ គេសម្រុកប៉ុន្មានតឹកមកហើយ ខ្លាំងៗ ធ្ងន់ធ្ងន់ពេកណាស់ សមដែរទេនៅយប់ដំបូងទើបរៀបការ។ គេអនុវត្តលើនាងដូចជាមនុស្សមានគំនុំ មិនមែនជាមួយប្រពន្ធដែលស្រឡាញ់ពេញចិត្ត។ គេក៏ចេះសួរ និងដឹងឮដែរថានាងឈឺដែរអីម្តេចនៅតែចង់បន្ត?

តែខាងប្រុសមិនខ្វល់នឹងភាសាភ្នែកដែលអង្វរករ គេខាំបបូរមាត់ស្អាតស្តើង និងលូកដៃទៅរកទីអាថ៌កំបាំងដែលនាងខំបែរភ្លៅត្បៀតបាំង។ គេទាញទន្ទឹងទន្ទែងជាមួយនាងរហូតដល់គ្រប់យ៉ាងអាក្រាតខ្វាំងទទេស្អាត នៅចំពោះមុខគ្មានអ្វីបិទបាំងទើបអស់ចិត្តមានៈ។

ពេលដែលរកតែនឹងឱនទ្រោបក្បាលទៅរកក្បាលពោះរាបស្មើរបស់នាង ម៉ូស្តាកំណាចនេះនៅផ្អៀតងាកមកសម្លឹងមើលនាងជាមួយកែវភ្នែកវាហីចង់ប្រាប់ថាទារុណកម្មនេះទើបតែជាការចាប់ផ្តើមទេចន្ទកាន។

ចន្ទកានជាកូនក្រមុំរបស់គេ។ ពួកគេទើបតែរៀបការ នាងមិនដឹងថាគ្រប់យ៉ាងជាគម្រោងទេ។

តូចតន់លូកដៃស្តើងៗមកខ្ទប់បាំងឃាត់មុខគេដែលឱនមក។

«គេងទៅប្តី យប់ជ្រៅហើយ!»

ពាក្យសម្តីរបស់ចន្ទកានហាក់ចាក់ទម្លុះបេះដូងរឹងមាំកកស្ទះទៅដោយគំនុំរបស់ម៉ូស្តា។ ទោះស្រីកាន់តែទន់ភ្លន់ មិនទ្រគោះបោះបោកខឹងកើតទោសៈដាក់ប្តី តែសម្តីនាងនៅតែផុយដូចអាវុធច្រេះចាក់មកបេះដូងទឹកកកនេះបានត្រឹមមួយភឹបដួលរលាយខ្សុលខ្លួនឯង។

បេះដូងនេះនៅតែមិនទន់ជ្រាយ។

ម៉ូស្តាចចេសវាសដៃនាង ចេញបង្ខំឱនថើបពាសពេញរាងកាយតូចយ៉ាងរន្ថើនតាមចិត្តគេប៉ុនប៉ង។ ព្រោះប្រុសរំពឹងទុកឱ្យនាងខឹង ដេរប្រទេច ឆ្មាស់ឆ្មើមដាក់ នឹងអាលគេបានលេសដាល់នាងឱ្យជាំពេញខ្លួនក្នុងយប់ផ្សំដំណេក បង្ហាញផ្ញើនឪពុកនាងនៅពេលព្រឹកឡើង។

នាងមិនធ្វើ បែរជាយំតិចៗព្រោះឈឺខ្លួនពន់ពេក។

ម៉ូស្តាពន្យឺតសង្វាក់ថើប សំឡេងមួយសួរគេឡើងថា ហេតុអ្វីខ្ញុំត្រូវធ្វើបាបមនុស្សស្រីម្នាក់ដែលបន្តនិយាយល្អៗជាមួយខ្ញុំ ហេតុអ្វីចិត្តមួយចេះតែបានមករារាំងខ្ញុំមិនឱ្យធ្ងន់ដៃតាមគំនុំ៨ឆ្នាំ?

ប៉ុន្តែម៉ូស្តានៅតែចចេស ចង់មើលថាតើកូនស្រីអ្នកមានអាចដាក់អត់ទ្រាំនឹងការឈឺពោះឈឺកាយ ឈឺគ្រប់កន្លែងជាមួយភាពឃោរឃៅនេះបានដល់ព្រឹកទេ?

គិតហើយប្រុសបោះប្រមុះឡើងមកលើទ្រូងសងខាង ដែលនៅក្រហមរលាក ធ្វើឲ្យនាងក្រញៀងខ្លួន រើបម្រះព្រោះខ្លាចឈឺបន្ថែមពីលើកាយដែលកំពុងឈឺស្រាប់ ប៉ុន្តែហត្ថទាំងទ្វេរបស់នាងត្រូវគេគ្រងចាប់អស់ ក៏កម្លាំងរើបានត្រឹមតែរេខ្លួនតិចៗដោះមិនរួចពីទណ្ឌកម្មកំណាចឡើយ។ដោយសារឈឺខ្លាំង និងឆ្ងល់ចំពោះភាពគ្មានករុណារបស់ប្ដីហើយបានជានាងនិយាយតិចៗ៖

«ហេតុអី?»

គេនៅតែមិនខ្វល់ឆ្លើយអ្វីទាំងអស់។ ស្រីខំនិយាយអង្វរទៀតយ៉ាងរអាក់រអួល៖

«អូនឈឺខ្លួនណាស់ចាំស្អែកទៅណា!»

ហិង្សាព្រមពាក្យទន់ ចិត្តនាយរឹតតែខំធ្វើរឹងដូចជាមិនមានបេះដូងមិនចេះអាណិត។ តែតាមពិតគេក៏ ជាមនុស្សមិនមែនជាសត្វតិរិច្ឆានទេ គេបន្តនេះមិនបានយូរសោះរកតែបែរខ្នងប្រះដេកតាមនាងអង្វរដែរស្រាប់តែងាកឃើញបន្ទប់នេះសែនទំនើបឥតខ្ចោះ ជាផ្ទះកូនក្រមុំដែលមានឪពុកជាសេដ្ឋីលួចទ្រព្យអ្នកដទៃ។

គេនឹកដល់ថ្ងៃដែលឪពុកនាងបានបណ្ដេញបងប្រុសគេចេញពីកន្លែងធ្វើការ ប្លន់គ្រប់យ៉ាងដែលពុកគេនិងបងគេខំសាងមកជាមួយយូរមកហើយ ទាំងក្ដីអាម៉ាស់យប់ដដែលបងគេក្រឡាប់ឡានស្លាប់តែឯងព្រោះខូចចិត្ត។ ពេលបុណ្យសពបងប្រុសមិនទាន់ចប់ផង បងប្រុសរបស់នាងបានផ្ដាច់ពាក្យជាមួយបងស្រីរបស់គេទាំងគ្មានហេតុផលទោះជាពួកគេភ្ជាប់ពាក្យ

ជាមួយគ្នាយូរមកហើយ ប្រហែលដោយសារតែឃើញឪពុកយើងស្លាប់ រឞររកស៊ីឆក់ដណ្ដើមអស់។

ក្រោយពេលដែលឪពុកម៉ូស្ហាស្លាប់បាត់បង់ជីវិតព្រោះគាំងបេះដូង អ្នកម្ដាយគេទទួលយកការពិតមិនបានក៏ខកចិត្តទន់ខ្សោយទៅស្នាក់នៅក្នុងមន្ទីរពេទ្យច្រើនជាងនៅផ្ទះ។

ម៉ូស្ហាដឹងថាបងប្រុសធំគេនៅមានហ៊ុនតិចតួចនៅសល់ក្នុងក្រុមហ៊ុននេះក៏ត្រូវឪពុកចន្ទកានដកតំណែងធំចេញរហូតខូចចិត្តបើកឡានគ្មានគោលដៅដល់គ្រោះថ្នាក់ស្លាប់។ គេគិតម្នាក់ឯងដោយឈឺចាប់ថា ទីបំផុតសូម្បីទំនាក់ទំនងចុងក្រោយរបស់គ្រួសារយើង គឺការភ្ជាប់គ្នារវាងបងស្រីខ្ញុំនិងបងប្រុសធំគេក៏ត្រូវផ្ដាច់ដែរ។ បងស្រីខ្ញុំដែលធ្លាប់តែជាមនុស្សផ្ដល់ភាពកក់ក្ដៅស្លូតបូត ចេះលួងលោមប្អូន មិនឲ្យប្អូនបាក់ទឹកចិត្តទីបំផុតគាត់បានបាក់ទឹកចិត្តដោយស្ងប់ស្ងាត់ខ្លួនឯង និងជ្រើសរើសយកផ្លូវមួយដែលគ្មានអ្នកណាស្មានមិនដល់។

គិតហើយគេគម្រាមកូនក្រមុំតិចៗថា ៖

«ឈឺស្អី? ទើបតែលើកទីបួន! ស្រីគេដេកជាមួយប្រុសៗដប់ម្ភៃនាក់ផង!»

គេបញ្ចេះកំហឹងចិត្តខ្លួនឯងនិងសួរនាងទាំងមួម៉ៅក្ដៅចិត្តរួចចាប់ផ្ដើមសម្រុកសារជាថ្មី ទៅកាន់សមរភូមិដែលខ្មាំងត្អូញថាឈឺចាប់មិនចង់ប្រយុទ្ធតទល់ទៀតឡើយ។

ទីណាដែលនាងចង់រាំងគេកាន់តែសម្រុកទៅទីនោះ ធ្វើឲ្យលើកនេះទឹកបាក់ទំនប់កានស្រែកទ្រហោយំលាន់ចេញមកពាសពេញបន្ទប់ផ្សំដំណេក។

«ម៉ូស្ហាៗឈប់ទៅ ខ្ញុំឈឺខ្លាំងណាស់»

ខាងប្រុសហត់គយូសនៅក្រោមការសម្ដែងកម្លាំងដាក់ទណ្ឌកម្មដែលខ្លួនបានបង្វឹករង់ចាំអស់ពេលជាយូរមកហើយ។  ទីបំផុតគេអាចធ្វើឱ្យស្រីម្នាក់នេះចុះនរកបានហើយ ទាំងនាងយំស្រែកដូចបែកអាកាសដៃនាងញ៉ូវទប់ស្មាគេមាត់ស្លាំង ទឹកមុខឈឺចាប់បែបណាក៏ប្ដីកំណាចមិនព្រមឈប់ រហូតទាល់តែបានសម្រេចបំណងលើកទីបួនហើយផ្ងារទៅម្ខាងដេកសម្រាកធ្វើព្រងើយ។

សាច់ខ្នងស្រីដែលនៅប៉ះពីក្រោយខ្នងម៉ូស្ហារង្កើខ្លាំងណាស់ ដូចជាមានន័យថានាងយំគគ្រូកខូចចិត្តដោយប្ដីមិនខ្វល់មិនចេះថ្នាក់ថ្នម។

ខាងប្រុសញញឹមម្នាក់ឯង។ គេគិតថាទោះបីជាកានឈឺចិត្តឬក៏ឈឺខ្លួន គេគួរសប្បាយចិត្តទាំងអស់ បន្ថែមពីនោះប្រុសនិយាយឱ្យទាំងមិនបែរមើលនាង៖

«បានយំហើយយំឱ្យខ្លាំង កុំភ្លេចយំម៉ាហើមភ្នែក ព្រោះស្អែកហ្នឹងប៉ាអូន បងប្រុសរបស់អូនមកញ៉ាំកាហ្វេជាមួយគ្នា ដើម្បីបានឃើញថា កូនក្រមុំមានសុភមង្គលយ៉ាងម៉េចខ្លះកាលពីយប់ផ្សំដំណេក!»

គ្មានជម្រើសទេពេលកានឮខ្ញុំនិយាយដូច្នេះរងកាយត្រូវកម្ទេចជាចម្រៀករបស់នាងដែលមិនសមថាស្អែកក្រោកដើររួចនេះខំបែរមករកខ្ញុំ លើកដៃមួយមកដាក់លើខ្ញុំ។

«កុំហៅពួកគេអី!»

នាងនិយាយតិចៗ ។

ម៉ូស្គាច្បាស់ហើយថាស្រីកានរបស់គេ កុំថាឡើយចេញទៅញ៉ាំកាហ្វេជួបបងប្រុសនាង ឬជួបឪពុករបស់នាង ឬជួបមនុស្សក្នុងផ្ទះនេះ ប្រហែលតែក្រោកទៅបន្ទប់ទឹកផងក៏ទៅមិនរួចដែរ ។ ប្រុសគ្រវាសខ្លួនក្រោកចោលដៃស្រឡូនរបស់នាង។

គេដើរយ៉ាងមាំទ្បយឆាយសំដៅមកក្នុងបន្ទប់ទឹកដ៏ធំមួយលុបលាងមុខខ្លួនឯងខណៈទ្រូងនេះពោរពេញទៅដោយជ័យជម្នះ។ ម្ចាស់គំនុំឈរយ៉ាងយូរសម្លក់កែវភ្នែក ត្រជាក់ដូចទឹកកករបស់គេចិត្តមួយនិយាយស្ងាត់ថា បងលីសា បងម៉ូណា អ្នកទាំងពីរនៅឋានសួគ៌មានឃើញខ្ញុំដែរ? ខ្ញុំកំពុងតែបានសងសឹកហើយ! ឆាកទីមួយចាប់ផ្តើមហើយ! ទោះបីមិនសូវទាន់ល្អមើល ប៉ុន្តែនឹងល្អមើលជាងនេះទៀត! សូមវិញ្ញាណក្ខន្ធបងៗទៅកាន់សុគតិភព! អាចន្ទរ៉ុជ អាប្រុសក្បត់ចិត្តបងលីសា ជិតនឹងបានឃើញសភាពចុះនរករើមិនរួចរបស់ប្អូនស្រីវា ទាំងដើរមិនរួចភ្នែកហើមមិនបានដេក ស្គមស្គាំង ល្ហិតល្ហៃ កែងជាមនុស្សទៀត។

នេះជាអ្វី តែខ្ញុំគ្រាន់តែជូនជំនូនដល់គ្រួសារវាជាដំបូងតែប៉ុណ្ណឹង មានរឿងច្រើនទៀតពួកវាស្មានមិនដល់ទេ ។

ប្រុសគិតសប្បាយចិត្តឱបភ្លើងក្តៅឡើងៗ បែរភ្លេចថាអ្នកណាម្នាក់កំពុងឈានមកពីក្រោយខ្នង។ គេជាមនុស្សដែលខ្លួនទើបតែបានរៀបការជាមួយពីព្រឹក នាងឈ្មោះចន្ទកាន គឺជាកូនស្រីពៅនៃគ្រួសារនេះ ក៏ជា គ្រួសារដែលគេបានស្អប់ពេញក្នុងមួយជីវិតនេះទៅទៀត។

ទោះបីពួកគេស្លាប់សូន្យអស់ក៏នៅ មិនអាចសងបាននូវការឈឺចាប់ដែលបានបង្កើតមកលើដើមទ្រូង គ្មានខោអាវរបស់គេក្នុងពេលនេះផងទេ។

ម៉ូស្ដាធ្វើមុខឌឺមិនញញឹម តែបែរក្រោយផ្អែកខ្លួនទៅលើឡាបូលាងដៃ ក្រពាត់ហត្ថាសម្លឹងប្រពន្ធតូចដែលដើរមកដូចជាមនុស្សមានជំងឺ។

គេធ្វើហីពេលខាងស្រីទាញយកកន្សែងពោះគោសមួយលើជញ្ជាំងមកព័ទ្ធបិទបាំងជុំវិញចង្កេះ។

សក់កានរញ៉េរញ៉ៃ គ្របពាសពេញស្មានិងដើមដៃ ដើមទ្រូង។ ភ្នែកនាងហើម មាត់ក្រហមៗ មុខស្លេក ដៃជើងតូចស្គមឡើងៗដូចមានតែឆ្អឹង។

«ប្ដីកុំហៅប៉ានិងបងធំមកញ៉ាំកាហ្វេស្អែកអី ចាំថ្ងៃក្រោយទៅបានទេ?»

ប្រុសបិទមាត់មិនឆ្លើយទោះបីនរៈនៅសម្លឹងចំភ្នែកប្រពន្ធសម្ងប់ ចាំមើលថានាងដោះស្រាយយ៉ាងម៉េចជាមួយនឹងគោលបំណងគេដេលកំពុងចង់ទូទាត់បំណុលជីវិត។

នាងរុំកន្សែងដែរត្រឹមទ្រូងតែខ្លួននេះមើលទៅកាន់តែរួមតូចឡើងដូចជាប្រយុទ្ធគ្នាម្ដងស្ទិតសាច់អស់ម្ដងដឹង?

កានសម្លឹងម៉ូស្ដា ទឹកមុខនាងស្រពោន លើកម្រាមទាំង១០មកកាន់ថ្នមកដៃរបស់ប្ដី

«យល់ព្រមណា កុំជួបអ្នកណាអីយើងទើបតែរៀបការរួច»

ម៉ូស្ដាលើកដៃរលាស់ម្រាមដៃតូចចេញភ្លាមៗ។ ចន្ទកានជ្រួញចិញ្ចើមព្រោះហាក់ដូចជាងឿងឆ្ងល់ចំពោះគេ ម្ដេចចេញចរិតមកដូចជាស្អប់ខ្ពើមនាង?

ប្ដីម្នាក់នេះបានរួមសង្វាស់ជាមួយនាងបួនដងហើយ តែគេគ្មានស្នាមញញឹមសូម្បីតែម្ដងផង។ ក្នុងជំនួបដដែលនេះ នាងអាចនឹងច្រឡំថា គេស្រឡាញ់នាងខ្លាំងទប់ចិត្តមិនបានដឹង?

គិតហើយ បានជាម៉ូស្ដារលាស់ដៃកានចេញស្រែកថាឱ្យឮៗ៖

«ញិកញ៉ក់កាន់ដៃជើងស្អី? ពុតត្បុត!»

នាងងើបមុខសម្លឹងគេទាំងរលើងរលោងហើយសួរ៖

«បងកើតអី? មួយថ្ងៃនេះខឹងចិត្តជាមួយអ្នកណា? បងខឹងរឿងអី?ចេញចរិតប្លែកៗ»

ម៉ូស្គាមានបំណងមិនប្រាប់ហេតុផល ប៉ុន្តែពេលនេះឮនាងសួរគេចង់ឱ្យនាងដឹងឱ្យហើយថា គេចង់កម្ទេចនាង មិនមែនចង់យកមកជាភរិយាទេ។ សង្កត់នាងបួនដងនេះមិនមែនអត់សម្រស់នាងមិនបានឡើយ។ គេជាមនុស្សមិនចេះនិយាយច្រើនប៉ុន្តែចាំនិងគុំរឿងនីមួយៗយូរណាស់ ។

នៅពេលកានសម្លឹងគេដូចជាចង់បានចម្លើយខ្លាំង ម៉ូស្គាខាំមាត់និយាយៈ

«គ្មានកើតស្នេហ៍ទាំងអស់ កើតរោគចិត្ត ចង់ដេកជាមួយគ្នាអត់ឈប់មួយយប់ដល់ភ្លឺ ឮ?»

ប្រុសមាឌមាំនិយាយចប់កាលណាដើរកៀសចេញពីនាង បុកស្មាស្រីដែលកំពុងទប់សឹងរបូតចេញពីទីតាំងនាងឈរ។

ម៉ូស្គាមិននិយាយប្រាប់នាងអ្វីទៀតទាំងអស់។ នាងមិនដឹងការពិត មិនដឹងគេជាអ្នកណាក៏ទុកឲ្យនាងដោះស្រាយបញ្ហាដោយស្ងាត់ស្ងៀមបែបនេះទៅ។

គេចាកចេញទៅឈរមកវេរ៉ង់ដា មិនខ្វល់ថាខ្លួនប្រាណនៅអាក្រាតផ្នែកលើបង្ហួតមេឃបង្ហួតផ្កាយនូវអង្គត់សាច់ហាប់ណែនទាំងលើទាំងក្រោមពោះ។ ប្រុសសម្លឹងទៅទីក្រុងលាតសន្ធឹងដោយញញឹមកំណាចម្នាក់ឯង  ព្រោះថាមេឃកំពុងយុត្តិធម៌ផ្តល់មកឲ្យគេ លើកជូនគេនូវអ្វីមួយដែលគេប៉ងប្រាថ្នាជាយូរណាស់មកហើយ។

បានជាន់ឈ្លីមនុស្សស្រីម្នាក់ជាត្បូងកែវនៃគ្រួសារមួយនេះ ទោះពួកគេមិនទាន់ដឹងថានាយជាអ្នកណា ហើយមិនដឹងថា ច្រើនឆ្នាំមកនេះបន្ទាប់ពីបាត់បង់បងប្រុសនិងបងស្រី គេបានតស៊ូរស់ដោយរបៀបម៉េចខ្លះ ក៏ពួកមហាសេដ្ឋីដូចគេ ដល់ពេលសងបំណុលចាស់ថ្មីឡើងទ្រោមហើយ។

មិនយូរទេ គេនឹងដឹងថាកូនស្រីគេរៀបការហើយ មិនមានអ្នកបម្រើឆ្វេងស្តាំដូចទម្លាប់ ដែលពួកគេទំយើរនាង ថែមទាំងត្រូវមកបម្រើប្តីដែលមានចរិតឆ្កួតលីលាតាំងពីព្រឹកដល់ល្ងាចបែបនេះ តើពួកគេទទួលយកបានទេ សើចសម ជល់កែវសមទៀតដែរ?

ងូតទឹកទៅ នឹងបានមកតភាគទៀត!

គេបញ្ជាទាំងមិនបែរខ្នងមកមើលនាងទេ។

ស្វាត់ណាស់ មិនឮអ្វីសោះ ប្រុសនៅជំអក់បន្តិចទើបដើរបកមកក្នុងវិញ។ សភាពខាងក្នុងខុសគម្រោងកុនសងសឹករបស់គេបន្តិចហើយ។ កានទប់មិនរួចទេ នាងកំពុងគេងសន្លប់ឈើលើឥដ្ឋក្បែរទ្វារបន្ទប់ទឹក។

គេឈរសម្លក់រាងតូចដែលដេកមិនដឹងប្រាណក្នុងសំណុំកន្សែងពោះគោក្រាស់។ នាងឈឺចាប់ឬនាងតក់ស្លុតពេកពេលដែលឮថា រៀបការប៉ះចំប្តីរោគចិត្ត?

«ក្រោកឡើងចន្ទកាន!»

ប្រុសបញ្ជា។

នាងនៅតែបន្តស្លូកស្ពឹងបិទភ្នែកស្លុប។

«ស្រីមាយា!»

ម៉ូស្តាដើរទៅក្បែរនាងដោយច្រត់ចង្កេះឱនមើល។

គួរហៅបងប្រុសនាង និងឪក្មេកសំណព្វឡើងមកមើលសភាពកូនក្រមុំសន្លប់ដែរទេ?

ប្រុសឱនមកលើកត្រកងភរិយាឡើង។

គេចាប់អារម្មណ៍ថាប្រាណនាងក្រៅរោល។

ឡើងកម្តៅ?

គេសួរខ្លួនឯងហាក់ស្លន់ស្លោ។ មាឌធំដាក់ស្រីទៅលើសាឡុងទាញសណ្តូកជើងនាង វាសសក់ចេញពីទឹកមុខដែលបែកញើសស្និត រួចបែរទៅរកមើលយូរកាបូបគ្រឿងពេទ្យរបស់ខ្លួនមកដល់។ ប្តីស្ទង់កម្តៅឱ្យនាង រួចផ្ទៀងសម្លឹងនាងពីលើដល់ក្រោម។

បបូរមាត់ដ៏ស្អាតឥតបី ពោលពាក្យសម្រាប់ខ្លួនឯងទាំងអាការៈបារម្ភថា៖

«ក្តៅម្ល៉េះ? កុំប្រាប់ថាប៉ុណ្ណឹងសោះស្លាប់ដែរណ៎ាចន្ទកាន!»